**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ២៦៩៦ ព.ណ.អ.ន.ព

ថ្ងៃព្រហ ៤រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ពាណិជ្ជករ អាជីវករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ សភាពាណិជ្ជកម្មអន្តរជាតិប្រទេសចិនក្រុមប្រឹក្សាសម្រាប់ការជំរុញពាណិជ្ជកម្មអន្តរជាតិខេត្តយូណានរដ្ឋបាលក្រុងគុនមិញ និងក្រុមហ៊ុន Yunnan Metropolitan Construction Investment នឹងសហការរៀបចំ **"ពិព័រណ៍មេគង្គ-ឡានឆាង"** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅខេត្តយូណាន ប្រទេសចិន។

ពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិដ៏ធំមួយ ត្រូវបានទទួលស្គាល់ ទាំងក្នុងតំបន់ និងពិភពលោកហើយទទួលបានជោគជ័យជាច្រើនឆ្នាំមកហើយដោយផ្ដោតលើផលិតផលចម្រុះដែលមានគុណភាពខ្ពស់។ ពិព័រណ៍ពាណិជ្ជកម្មនេះនឹងត្រូវរៀបចំឡើងដោយមានការចូលរួមពីបណ្ដាក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិជាច្រើន មកពីបណ្ដាប្រទេសនានានៅក្នុងតំបន់អាស៊ាន និងពិភពលោក (អ្នកចូលរួមនឹងមានចំនួន ១០,០០០ក្រុមហ៊ុន) ដោយមានការដាក់តាំងបង្ហាញនូវផលិតផលគុណភាពខ្ពស់ ដូចជាគ្រឿងអនុស្សាវរីយ៍ សម្ភារៈគេហដ្ឋាន សុខភាព និងសម្រស់ សម្លៀកបំពាក់ ផលិតផលសម្រាប់ទារកនិងកុមារ អាហារ និងភេសជ្ជៈ និងបច្ចេកវិទ្យាឆ្លាតវៃផ្សេងៗទៀត ក្នុងគោលបំណងដើម្បីពង្រឹងនិងបន្តពង្រីកទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាងចិន-កម្ពុជា។ ក្នុងឱកាសនេះដែរ ភាគីចិនបានផ្ដល់ស្តង់ដោយឥតគិតថ្លៃមួយចំនួនសម្រាប់ភាគីកម្ពុជា ដើម្បីដាក់តាំងបង្ហាញផលិតផល និងសេវាកម្មរបស់ខ្លួន ក៏ដូចជាការស្វែងរកដៃគូពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញពាណិជ្ជករ អាជីវករ ដែលជាម្ចាស់ក្រុមហ៊ុន និងសហគ្រាសទាំងអស់ ដែលមានចំណាប់អារម្មណ៍ និងបំណងទៅចូលរួមផ្សព្វផ្សាយពីផលិតផល ឬសេវាកម្មរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្មក្នុងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មនេះ សូមមកទាក់ទង និងបំពេញបែបបទ នៅនាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវពាក្យស្នើសុំចូលរួម និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩។ ក្រសួងពាណិជ្ជកម្មសូមរក្សាសិទ្ធិផ្ដល់អាទិភាពជូនពាណិជ្ជករ អាជីវករ ដែលអញ្ជើញមកទាក់ទងបានមុន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទី៣ នៃអគារទីស្ដីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍ លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១២ ៦០០ ៧៧៨ ឬ ០១២ ៧៧៧ ៩៥៩ ឬ ០៨៩ ៩១ ១១ ០១
អាសយដ្ឋានអ៊ីម៉ែល៖ cheaputhea@yahoo.com/ veasna_mao@yahoo.com/ sanphirun[illegible]gmail.com

សូមអរគុណ!

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°2632 MOC/D/EA

Phnom Penh, July 17 2019

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all the traders and entrepreneurs that China Chamber of International Commerce, China Council for the Promotion of International Trade Yunnan Sub-Council, Kunming Municipal People's Government and Yunnan Metropolitan Construction Investment Group will organize the **"The Lancang-Mekong Cooperation Exposition (LMCE)"** to be held from November 21-25, 2019 at Kunming International Convention and Exhibition Center, Yunnan Province, China.

The LMCE will consist of three major parts: Forum, Exhibition, & Conference showcasing varieties of products including home appliances, health and cosmetics, souvenirs, textiles and footwear, baby products, food and beverages, and smart technologies. The organizing committee will invite 10,000 international exhibitors to participate in the LMCE.

In this regard, the Ministry of Commerce is pleased to invite all interested traders and entrepreneurs who wish to showcase their products or look for trade partners to attend the above-mentioned event.

For further information and registration, please contact Department of Exhibition Affairs of the General Directorate of Trade Promotion, The Ministry of Commerce by October 20, 2019 at the address below:

Department of Exhibition Affairs, General Directorate of Trade Promotion,
The Ministry of Commerce:
Lot No. 19-61, Russian Federation Blvd,
Phum Toek Thla, Sangkat Toek Thla,
Khan Sen Sok, Phnom Penh.
Tel: 012 777 959 / 012 600 778 /089 911 101
E-mail: cheaputhea@yahoo.com/ veasna_mao@yahoo.com/ sanphirun1977@gmail.com

THANK YOU!